KHMER

## សកលវិទ្យាល័យនៃរដ្ឋកាលីហ្វ័រនីញ៉ា ក្រុងឡូសអែនជឺឡេស

## សិទ្ធិផ្លូវច្បាប់

របស់អ្នកចូលរួមក្នុងការសិក្សាស្រាវជ្រាវ

សិទ្ធិទាំងអស់នេះ គឺជាសិទ្ធិរបស់បុគ្គលគ្រប់រូប ដែលត្រូវបានគេស្នើសុំឱ្យចូលរួមក្នុងការសិក្សាស្រាវជ្រាវផ្នែកវេជ្ជសាស្ត្រ ។ ក្នុងនាមជាអ្នកចូលរួមលើការសិក្សាស្រាវជ្រាវ ខ្ញុំមានសិទ្ធិដូចខាងក្រោម :

1. ខ្ញុំមានសិទ្ធិ ដើម្បីបានដឹងនូវគោលបំណងនៃកាសិក្សាស្រាវជ្រាវ ។

2. ខ្ញុំមានសិទ្ធិ ដើម្បីបានដឹងនូវទំរង់ការនៃការស្រាវជ្រាវ ការប្រើប្រាស់ឱសថ និង/ឬ បរិក្ខារទាំងអស់ ព្រមទាំងមានសិទ្ធិដឹង ថាតើការប្រើឱសថ ឬបរិក្ខារទាំងនេះ វាខុសពី អ្វីដែលគេប្រើ លើការអនុវត្តន៏ជាស្តង់ដា ដែរឬទេ។

3. ខ្ញុំមានសិទ្ធិ ដើម្បីបានដឹងនូវ ភយន្តរាយ ភាពមិនស្រួល ឬផលប៉ះពាល់ដែលមិនបានរំពឹងទុក ដែលជាហេតុផលអាចកើតឡើង ចំពោះលទ្ធផលនៃការសិក្សាស្រាវជ្រាវនេះ ។

4. ខ្ញុំមានសិទ្ធិ ដើម្បីបានដឹងនូវ ផលប្រយោជន៏ដែលនឹងបានទទួល ប្រសិនបើមាន ដែលជាហេតុផលសមរម្យ ខ្ញុំអាចរំពឹងទុក ពីការចូលរួមលើការ សិក្សាស្រាវជ្រាវនេះ ។

5. ខ្ញុំមានសិទ្ធិ ដើម្បីបានដឹងនូវ ជំរើសដទៃទៀតសំរាប់ព្យាបាលរូបខ្ញុំ ព្រមទាំងមានសិទ្ធិបានដឹងថាតើជំរើសទាំងនោះប្រសើជាង ឬអាក្រក់ជាងពីការចូលរួមលើការសិក្សា ស្រាវជ្រាវនេះ ។ ជំរើសទាំងនេះ អាចរួមបញ្ចូលនូវទំរង់ការ ការប្រើឱសថ ឬការប្រើ បរិក្ខារផ្សេង ទៀតលើការព្យាបាល ។

6. ខ្ញុំមានសិទ្ធិ ដើម្បីបានដឹងនូវ វិធីផ្សេងទៀតសំរាប់ព្យាបាល ប្រសិនបើការសិក្សាស្រាវជ្រាវនេះ ជួបប្រទះនូវភាពស្មុគ្រស្មាញនានា ។

7. ខ្ញុំមានសិទ្ធិ លើការមានឱកាសសួរនូវសំណួរផ្សេងៗ លើការសិក្សាស្រាវជ្រាវ ឬទំរង់ការនៃការសិក្សាស្រាវជ្រាវ ។ ខ្ញុំអាចសួរនូវសំណួរទាំងនេះ នៅមុនការសិក្សាស្រាវជ្រាវចាប់ផ្តើម ឬអាចសួរបានគ្រប់ពេល ក្នុងពេលកំពុងធ្វើការសិក្សាស្រាវជ្រាវ ។

8. ខ្ញុំមានសិទ្ធិ បដិសេធមិនចូលរួម ឬមានសិទ្ធិឈប់ចូលរួម លើការសិក្សាស្រាវជ្រាវនេះ បានគ្រប់ពេល ។ ការសំរេចចិត្តនេះ នឹងមិនមានផលប៉ះពាល់ ដល់ការព្យាបាលរបស់ខ្ញុំ ឬទំនាក់ទំនងរវាងខ្ញុំនឹងលោកវេជ្ជបណ្ឌិតដែលផ្តល់ការព្យាបាលដល់រូបខ្ញុំ ឬទំនាក់ទំនង ជាមួយ នឹងវិទ្យាស្ថាននេះឡើយ ។

9. ខ្ញុំមានសិទ្ធិ ដើម្បីបានទទួលនូវច្បាប់ថតចម្លងលើការយល់ព្រមរបស់ខ្ញុំ ដែលមានសរសេរជាលាយល័ក្ខណ៏អក្សរ មានចុះហត្ថលេខា និងកាលបរិច្ឆេទ ចំពោះការចូលរួមលើការសិក្សាស្រាវជ្រាវនេះ ។

10. ខ្ញុំមានសិទ្ធិ មិនស្ថិតនៅក្រោមការគាបសង្កត់ណាមួយ ក្នុងការសំរេចចិត្ត ចង់ចូលរួម ឬមិនចូលរួមលើការសិក្សាស្រាវជ្រាវនេះ ។

---------------------------------------------------

បើខ្ញុំមានសំណួរ ឬការព្រួយបារម្ភណាមួយ ខ្ញុំអាចសួរអ្នកសិក្សាស្រាវជ្រាវ ឬជំនួយការអ្នកសិក្សាស្រាវជ្រាវបាន ។ ខ្ញុំក៏អាចទាក់ទងជាមួយនឹងការិយាល័យ សំរាប់ការពារអ្នកប៉ះពាល់លើការសិក្សាស្រាវជ្រាវ (OPRS) ដែលមានតួនាទីជួយការពារអ្នក ចូលរួមលើការសិក្សាស្រាវជ្រាវ ។ ខ្ញុំអាចទំនាក់ទំនងជាមួយនឹង OPRS តាមរយៈទូរស័ព្ទលេខ 310-825-8714 ចាប់ពីម៉ោង 8:00 នាទីព្រឹក ដល់ម៉ោង 5:00 នាទីល្ងាច ពីថ្ងៃច័ន្ទ ដល់ថ្ងៃសុក្រ ។ បើខ្ញុំហៅទូរស័ព្ទទៅកាន់ការិយាល័យនេះ ហើយគេមិននិយាយភាសាអង់គ្លេស ឬភាសាអេស្ប៉ាញ ខ្ញុំនឹងមានបុគ្គលិកណាម្នាក់ទំនេរ សំរាប់ជួយបកប្រែភាសាឱ្យខ្ញុំ ។ ខ្ញុំក៏អាចសរសេរលិខិតទៅកាន់ OPRS បានដែរ ដោយការផ្ញើ ទៅកាន់អាសយដ្ឋាន: 1000 Kinross Avenue, Suite 102, Box 951694, Los Angeles, CA 90095-1694.